ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦១ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ឃុំ សង្កាត់ ទូទាំងព្រះរាជាណាចក្រកម្ពុជា

~~~~~~~

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០២/០៤០ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- បានឃើញអនុក្រឹត្យលេខ ៣០អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- យោងតាមសំណើរបស់ទេសរដ្ឋមន្ត្រី និងជាអនុប្រធានទី១នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

## សម្រេច

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅបង្កើតគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ឃុំ សង្កាត់ ទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីបំពេញបន្ថែមក្នុងរចនាសម្ព័ន្ធនៃអនុក្រឹត្យលេខ៣០អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

**មាត្រា ២.-**

នៅតាមឃុំ សង្កាត់នីមួយៗ មានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ឃុំ សង្កាត់ ដែលមានសមាសភាព :

| | |
|---|---|
| ១-មេឃុំ ឬចៅសង្កាត់ | ប្រធាន |
| ២-ជំទប់ទី១ ឬ ចៅសង្កាត់រងទី១ | អនុប្រធាន |
~~~~~~~

៣-ប្រធានប៉ុស្តិ៍នគរបាល រដ្ឋបាលឃុំ សង្កាត់ សមាជិក

៤-ប្រធានកម្រងសាលាបឋមសិក្សា សមាជិក

៥-ប្រធានមណ្ឌលសុខភាព ឃុំ សង្កាត់ សមាជិក

៦-ជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ សមាជិក

៧-អ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជា សមាជិក

៨-ភ្នាក់ងារសុខភាពសត្វ សមាជិក

៩-ព្រឹទ្ធាចារ្យក្នុងឃុំ សង្កាត់ សមាជិក

១០-ប្រធានភូមិ គ្រប់ភូមិ សមាជិក

១១-ស្មៀនឃុំ សង្កាត់ សមាជិក និងជាលេខាធិការ។

**មាត្រា ៣.-**

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ឃុំ សង្កាត់ មានតួនាទី និងភារកិច្ច :

-អនុវត្តគោលនយោបាយជាតិដែលពាក់ព័ន្ធក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ

-ផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ អំពីគ្រោះមហន្តរាយជាយថាហេតុ

-ធ្វើរបាយការណ៍ជាបន្ទាន់អំពីស្ថានភាពគ្រោះមហន្តរាយជូនគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ខណ្ឌ និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ក្រុង អំពីទំហំនៃការខូចខាត និងតម្រូវការជាក់ស្តែងផ្សេងៗតាមករណីនីមួយៗ

-ធ្វើប្រតិបត្តិការជួយសង្គ្រោះប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ពេលមានគ្រោះមហន្តរាយកើតឡើង

-ជាសេនាធិការរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ខណ្ឌ ក្នុងការងារកាត់បន្ថយគ្រោះមហន្តរាយ និងផ្តល់យោបល់ពីសកម្មភាពរបស់ស្ថាប័នអង្គភាពពាក់ព័ន្ធ សមាគមជាតិ ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការជាតិ និងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលដែលរួមចំណែកក្នុងការងារកាត់បន្ថយគ្រោះមហន្តរាយ និងភាពងាយរងគ្រោះនៅមុនពេល ក្នុងពេល និងក្រោយពេលមានគ្រោះមហន្តរាយក្នុងមូលដ្ឋានឃុំ សង្កាត់របស់ខ្លួន

-រៀបចំចងក្រងក្រុមប្រតិបត្តិការសម្រាប់ធ្វើសកម្មភាពរួមមាន : ១-ក្រុមសន្តិសុខ រុករក និងសង្គ្រោះ ២-ក្រុមសុខភាព និងអនាម័យ ៣-ក្រុមឆ្លើយតប និងព័ត៌មាន

-ជ្រើសរើសអ្នកស្ម័គ្រចិត្តចូលរួមបំពេញការងារក្នុងក្រុមប្រតិបត្តិការទាំងបីខាងលើ

-រៀបចំកម្មវិធីបណ្តុះបណ្តាលដល់ក្រុមប្រតិបត្តិការទាំងបីលើជំនាញទទួលខុសត្រូវ ព្រមទាំងអប់រំ ផ្សព្វផ្សាយការយល់ដឹងជាសាធារណៈដល់មូលដ្ឋានសហគមន៍ពីគ្រោះភ័យនៃគ្រោះមហន្តរាយ មុខសញ្ញាគ្រោះថ្នាក់ វិធានការគ្រប់គ្រងគ្រោះភ័យ

-ផ្តល់ព័ត៌មានដល់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ខណ្ឌ និងខេត្ត ក្រុង អំពីការកើតឡើងនូវមុខសញ្ញាគ្រោះថ្នាក់ជាបន្ទាន់

-លើកគម្រោងប្រើប្រាស់ថវិកា សម្ភារៈ បរិក្ខារ មធ្យោបាយប្រើប្រាស់ និងកម្លាំងសម្រាប់ធ្វើសកម្មភាពតាមដំណាក់កាលនីមួយៗនៃការគ្រប់គ្រងគ្រោះមហន្តរាយដើម្បីដាក់ស្នើទៅថ្នាក់លើ និងទៅអង្គការនានា

-ធ្វើការប្រជុំមួយខែម្តងជាទៀងទាត់ ដើម្បីត្រួតពិនិត្យសកម្មភាព និងដោះស្រាយបញ្ហាដែលកើតមានរបស់ក្រុមប្រតិបត្តិការទាំងបី និងធ្វើការប្រជុំបន្ទាន់ក្នុងលក្ខណៈមានគ្រោះអាសន្ន។ ការប្រជុំនេះត្រូវធ្វើឡើងតាមការកោះអញ្ជើញរបស់ប្រធាន។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងគ្រប់អភិបាលខេត្ត ក្រុង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
អនុប្រធានទី១ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

**ញឹម វណ្ណដា**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**Kingdom of Cambodia**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Nation Religion King**

**គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ**
**National Committee for Disaster Management**
លេខ (Nº)..១៨១..គជ..គប

រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៦
Phnom Penh. ..............................

## ជំរាបជូន

### ឯកឧត្តម អភិបាលខេត្ត-ក្រុង និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ក្រុង

**កម្មវត្ថុ** : សេចក្តីណែនាំអនុវត្តន៍ ស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ សង្កាត់ទូទាំង ព្រះរាជាណា ចក្រកម្ពុជា

**យោង** : អនុក្រឹត្យលេខ ៦១ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៦ ស្តីពី ពីការបង្កើត គណៈកម្មាធិការ គ្រប់គ្រងគ្រោះមហន្តរាយឃុំ សង្កាត់ទូទាំង ព្រះរាជាណាចក្រកម្ពុជា ។

ដូចន័យដែលចែងក្នុងកម្មវត្ថុ និងយោងខាងលើ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ សូមធ្វើការណែនាំអនុវត្តន៍ ស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ សង្កាត់ទូទាំងព្រះរាជាណាចក្រកម្ពុជា ដូចខាងក្រោម :

## I. <u>នីតិវិធីការរៀបចំគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ សង្កាត់</u>

មេឃុំ-ចៅសង្កាត់ត្រូវចេញដីកាសំរេចបង្កើតគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ សង្កាត់របស់ខ្លួន ដែលមាន សមាសភាព :

| | | |
|---|---|---|
| ១. | មេឃុំ ឬ ចៅសង្កាត់ | ប្រធាន |
| ២. | ជំទប់ទី១ ឬ ចៅសង្កាត់រងទី១ | អនុប្រធាន |
| ៣. | ប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់ | សមាជិក |
| ៤. | ប្រធានកម្រងសាលាបឋមសិក្សា | សមាជិក |
| ៥. | ប្រធានមណ្ឌលសុខភាពឃុំ សង្កាត់ | សមាជិក |
| ៦. | ជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ | សមាជិក |
| ៧. | អ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជា | សមាជិក |
| ៨. | ភ្នាក់ងារសុខភាពសត្វ | សមាជិក |



Nº. 274, Bd. Monivong, Office: (855) 23 211 171 Fax: (855) 23 211 030

៩. ព្រឹទ្ធាចារ្យក្នុងឃុំ សង្កាត់ សមាជិក

១០. ប្រធានភូមិគ្រប់ភូមិ សមាជិក

១១. ស្មៀន សមាជិក និងជាលេខាធិការ

<u>បញ្ជាក់ :</u> សមាសភាពខាងលើគឺជាការចង្អុលបង្ហាញតែប៉ុណ្ណោះនៅពេលចេញដីកា ត្រូវកំណត់ឈ្មោះ បុគ្គលដែលមានតួនាទីខាងលើឱ្យបានច្បាស់ ។

## II. <u>រចនាសម្ព័ន្ធរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ សង្កាត់</u>

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ សង្កាត់មានរចនាសម្ព័ន្ធដូចតទៅ :

១. លេខាធិការដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ស្មៀនឃុំ សង្កាត់ ។

២. ក្រុមសន្តិសុខ រុករកសង្គ្រោះ ដែលស្ថិតនៅក្រោមការគ្រប់គ្រងដោយប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ជាប្រធាន និងប្រធានកម្រងសាលាបឋមសិក្សាជាអនុប្រធាន ដោយមាននគរបាលឃុំ សង្កាត់ គ្រូ និងសិស្សស្ម័គ្រចិត្តចូលរួមជាកំលាំងប្រតិបត្តិការ ។

៣. ក្រុមសុខភាព អនាម័យ ដែលស្ថិតនៅក្រោមការគ្រប់គ្រងដោយប្រធានមណ្ឌលសុខភាពឃុំ (ក្នុងលក្ខណៈដែលឃុំដែលពុំទាន់មានមណ្ឌលសុខភាពត្រូវយកអនុប្រធានមណ្ឌលសុខភាពពីឃុំរួមគ្នាមកទទួលគ្រប់គ្រង) ភ្នាក់ងារសុខភាពសត្វជាអនុប្រធាន និង ជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារជាអនុប្រធាន ដោយមានភ្នាក់ងារសុខភាពសត្វ និងក្រុមទ្រទ្រង់សុខភាព ជាកំលាំងប្រតិបត្តិការ ។

៤. ក្រុមឆ្លើយតប និងព័ត៌មានដែលស្ថិតនៅក្រោមការគ្រប់គ្រងដោយអ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជា ជាប្រធាន ព្រឹទ្ធាចារ្យក្នុងឃុំជាអនុប្រធាន និងអ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជា ជាកំលាំងប្រតិបត្តិការ ។

## III. <u>គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ សង្កាត់ មានតួនាទីនិងភារកិច្ច :</u>

- អនុវត្តគោលនយោបាយដែលពាក់ព័ន្ធ ក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ
- ផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋ ក្នុងឃុំ សង្កាត់ អំពីគ្រោះមហន្តរាយជាយថាហេតុ
- ធ្វើរបាយការណ៍ជាបន្ទាន់អំពីស្ថានភាពគ្រោះមហន្តរាយជូនគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ខណ្ឌ និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ក្រុង អំពីទំហំនៃការខូចខាត និងតម្រូវការជាក់ស្តែងផ្សេងៗ តាមករណីនីមួយៗ
- ធ្វើប្រតិបត្តិការជួយសង្គ្រោះប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ពេលមានគ្រោះមហន្តរាយកើតឡើង
- ជាសេនាធិការរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ខណ្ឌ ក្នុងការងារកាត់បន្ថយគ្រោះមហន្តរាយ និងផ្តល់យោបល់ពីសកម្មភាពរបស់ស្ថាប័ន អង្គភាពពាក់ព័ន្ធ សមាគមជាតិ ភ្នាក់ងារអង្គការ

សហប្រជាជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលដែលរួមចំណែកក្នុងការងារកាត់បន្ថយគ្រោះមហន្តរាយ និងភាពងាយរងគ្រោះនៅមុនពេល ក្នុងពេល និងក្រោយពេលមានគ្រោះមហន្តរាយក្នុងមូលដ្ឋាន ឃុំ សង្កាត់របស់ខ្លួន

- រៀបចំចងក្រងក្រុមប្រតិបត្តិការសំរាប់ធ្វើសកម្មភាព រួមមាន ១-ក្រុមសន្តិសុខ រុករក និងសង្គ្រោះ ២-ក្រុម សុខភាព និងអនាម័យ ៣-ក្រុមឆ្លើយតប និងព័ត៌មាន
- ជ្រើសរើសអ្នកស្ម័គ្រចិត្តចូលរួមបំពេញការងារ ក្នុងក្រុមប្រតិបត្តិការទាំងបីខាងលើ
- រៀបចំកម្មវិធីបណ្តុះបណ្តាលដល់ក្រុមប្រតិបត្តិការទាំងបីលើជំនាញទទួលខុសត្រូវ ព្រមទាំងអប់រំផ្សព្វផ្សាយការយល់ដឹងជាសាធារណៈដល់មូលដ្ឋានសហគមន៍ ពីគ្រោះភ័យនៃគ្រោះមហន្តរាយ មុខសញ្ញាគ្រោះថ្នាក់ វិធានការគ្រប់គ្រងគ្រោះភ័យ
- ផ្តល់ព័ត៌មានដល់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ខ័ណ្ឌ និងខេត្ត ក្រុង អំពីការកើតឡើងនូវមុខសញ្ញាគ្រោះថ្នាក់ជាបន្ទាន់
- ធ្វើគម្រោងប្រើប្រាស់ថវិកា សម្ភារៈ បរិក្ខារ មធ្យោបាយប្រើប្រាស់ និងកម្លាំងសម្រាប់ធ្វើសកម្មភាពតាមដំណាក់កាលនីមួយៗ នៃការគ្រប់គ្រងគ្រោះមហន្តរាយដើម្បីដាក់ស្នើទៅថ្នាក់លើ និងទៅអង្គការនានា
- ធ្វើការប្រជុំមួយខែម្តងជាទៀងទាត់ ដើម្បីត្រួតពិនិត្យសកម្មភាព និងដោះស្រាយបញ្ហាដែល កើតមានរបស់ក្រុមប្រតិបត្តិការទាំងបី និងធ្វើការប្រជុំបន្ទាន់ ក្នុងលក្ខណៈមានគ្រោះអាសន្ន ។ ការប្រជុំនេះត្រូវធ្វើឡើងតាមការកោះអញ្ជើញរបស់ប្រធាន ។

តួនាទីភារកិច្ចដែលបានកំណត់ខាងលើ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ សង្កាត់ត្រូវធ្វើការសំរបសំរួលអោយបានល្អ ជាមួយក្រសួង ស្ថាប័នរាជរដ្ឋាភិបាល អង្គភាពពាក់ព័ន្ធ សមាគមជាតិ ភ្នាក់ងារសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ដើម្បីសំរេចតួនាទី បំរើកិច្ចការមូលដ្ឋាន ។

## IV. <u>គ្រោងម៉ាស៊ីនដឹកនាំ និងតួនាទីភារទទួលខុសត្រូវរបស់ប្រធាន អនុប្រធាន គ.គ.ម.ឃុំ សង្កាត់ លេខាធិការ និង ក្រុមប្រតិបត្តិការ</u>

### ១.<u>ប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ សង្កាត់</u>

**<u>អាណត្តិប្រធាន</u>** : មេឃុំ ចៅសង្កាត់ ជាប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ សង្កាត់ ក្នុងអាណត្តិរបស់ ខ្លួនជាមេឃុំ ឬ ចៅសង្កាត់ ។

**តួនាទីរបស់ប្រធាន** :

- ដឹកនាំ និងសម្រេចកិច្ចការរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ សង្កាត់ ក្នុងនាមជាប្រធាន និងក្នុងក្របខ័ណ្ឌជាមេឃុំ និងចៅសង្កាត់ រួមទាំងការចុះហត្ថលេខាលើការបង្កើតគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ ក្រុមប្រតិបត្តិការទាំងបី ធ្វើការណែនាំការប្រកាសប្រាប់ឱ្យដឹងមុនពីគ្រោះអាសន្ននៅក្នុងឃុំ សង្កាត់របស់ខ្លួន និងធ្វើលិខិតកោះអញ្ជើញប្រជុំគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ សង្កាត់

-ដឹកនាំការប្រជុំរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ សង្កាត់

៥ -ធ្វើការសំរបសំរួល សហប្រតិបត្តិការ និងដឹកនាំការអនុវត្តន៍ គំរោងកម្មវិធីការងារគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយនៅមូលដ្ឋានសហគមន៍ ជាមួយស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងដៃគូនានា ដែលត្រូវ អនុវត្តនៅក្នុងឃុំ សង្កាត់របស់ខ្លួន។

-ដឹកនាំការងារប្រចាំថ្ងៃរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ សង្កាត់របស់ខ្លួន

-ដឹកនាំសំរបសំរួលសកម្មភាពត្រៀមបង្ការ កាត់បន្ថយគ្រោះថ្នាក់ និងត្រៀមរៀបចំឆ្លើយតបគ្រោះអាសន្ន និងការស្តារ ការស្ថាបនាឡើងវិញ ព្រមទាំងបញ្ជ្រាបការគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។

២. <u>**អនុប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ សង្កាត់**</u>

**អាណត្តិអនុប្រធាន** : ជំទប់ទី១ ចៅសង្កាត់រងទី១ ជាអនុប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ សង្កាត់ ក្នុងអាណត្តិរបស់ខ្លួន ជាជំទប់ទី១ និងចៅសង្កាត់រងទី១ ។

**តួនាទីរបស់អនុប្រធាន** : ជួយការងារប្រធាន និង ជំនួសប្រធាននៅពេលប្រធានអវត្តមាន។

៣. **លេខាធិការ** :

ជាសេនាធិការឱ្យប្រធាន និងអនុប្រធាន គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ សង្កាត់ ក្នុងការប្រមូលសរុបសភាពការណ៍ព្រឹត្តិការណ៍គ្រោះមហន្តរាយ និងសកម្មភាពរបស់ក្រុមទាំងបី ដើម្បីរាយការណ៍ជូនថ្នាក់បន្តបន្ទាប់ដែលទទួលការងារគ្រប់គ្រងគ្រោះមហន្តរាយ ហើយមានតួនាទី និងការ ទទួលខុសត្រូវលើការងារ :

-ទទួល និង ផ្តល់ព័ត៌មានបន្ទាន់ពីមុខសញ្ញាគ្រោះថ្នាក់ និងគ្រោះអាសន្នផ្សេងៗ ដោយមនុស្ស និងធម្មជាតិ

-ទទួលរបាយការណ៍ និងគ្រប់គ្រងទុកដាក់ឯកសារ

-ប្រមូលសរុបសភាពការណ៍ និង តាមដានត្រួតពិនិត្យវាយតំលៃ

-ធ្វើកំណត់ហេតុប្រជុំគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ សង្កាត់។

### ៤. ក្រុមសន្តិសុខ និងរុករកសង្គ្រោះ

ត្រូវបានបង្កើតឡើង ដើម្បីរៀបចំត្រៀមបង្ការមុខសញ្ញាគ្រោះថ្នាក់ ដែលបង្កឡើងដោយមនុស្ស និងធម្មជាតិ ធ្វើប្រតិបត្តិការនៅពេលមានគ្រោះអាសន្ន រំដោះប្រជាជនចេញពីគ្រោះថ្នាក់ ជម្លៀសប្រជាជន ការពារសន្តិសុខសុវត្ថិភាព ពន្លត់អគ្គីភ័យ រុករក និងសង្គ្រោះអ្នករងគ្រោះ ព្រមទាំងមានតួនាទីទទួលខុសត្រូវដូចខាងក្រោម :

-កំណត់មុខសញ្ញាគ្រោះថ្នាក់ ដោយធម្មជាតិ និងដោយមនុស្ស

-កសាងផែនការរៀបចំកំលាំងមធ្យោបាយ សំភារៈសំរាប់បំរើការរុករកនិងសង្គ្រោះ និងសន្តិសុខសណ្តាប់ធ្នាប់

-អប់រំផ្សព្វផ្សាយ និងពន្យល់ដល់ប្រជាពលរដ្ឋក្នុងឃុំ អំពីវិធានការត្រៀមបង្ការ កាត់បន្ថយគ្រោះថ្នាក់ ត្រៀមរៀបចំសំរាប់កាត់បន្ថយគ្រោះអាសន្ន និងគ្រោះភ័យផ្សេងៗ ព្រមទាំងខ្លឹមសារ និងសញ្ញាប្រកាសអាសន្ន និងសកម្មភាពត្រូវអនុវត្ត

-រៀបចំផែនទីមុខសញ្ញាគ្រោះថ្នាក់ ទីសុវត្ថិភាព និងគំនូសបង្ហាញផ្លូវពីកន្លែងមានប្រជាពលរដ្ឋរស់នៅ ទៅកាន់កន្លែងជម្លៀស ហើយនិងមានបញ្ជីប្រជាជនដែលអាចត្រូវជម្លៀស

-ដឹកនាំបុគ្គលិកសង្គ្រោះ និង សំរបសំរួល ធ្វើការបណ្តុះបណ្តាលជំនាញផ្នែកសង្គ្រោះបឋម និងជួយសង្គ្រោះ។

### ៥. ក្រុមសុខាភិបាល និងអនាម័យ

ត្រូវបានបង្កើតឡើងដើម្បីធ្វើប្រតិបត្តិការការពារអាយុជីវិតប្រជាជន តាមរយៈ ការគាំពារសុខភាព ស្រាវជ្រាវរកប្រភពនៃជំងឺ និង ការពារជំងឺឆ្លងទាំងមនុស្ស សត្វ ជំងឺរាតត្បាត ជម្លៀសអ្នកជំងឺទៅតាមកន្លែងមន្ទីរពេទ្យសង្គ្រោះបន្ទាន់ ហើយមានតួនាទីទទួលខុសត្រូវដូចខាងក្រោម :

-អប់រំ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យមានការយល់ដឹងពីការថែរក្សាសុខភាព ការទទួលទានចំណីអាហារ ការត្រៀមបង្ការមុខសញ្ញាគ្រោះថ្នាក់ដែលបង្កដោយមនុស្ស និងធម្មជាតិ

-បណ្តុះបណ្តាលជំនាញផ្នែកសង្គ្រោះបឋម ថែទាំសុខភាព អនាម័យដល់ប្រជាពលរដ្ឋ

-អប់រំផ្សព្វផ្សាយការយល់ដឹងជាសាធារណៈ ដល់ប្រជាពលរដ្ឋក្នុងឃុំអំពីរោគសញ្ញាផ្សេងៗនៃជំងឺសត្វ ក្នុងការការពារ ការព្យាបាលជំងឺសត្វ ការសំអាតអនាម័យទ្រុងសត្វ និងអនាម័យខ្លួនប្រាណមនុស្សការបរិភោគចំអិនសាច់សត្វ....

-រិះរកវិធីសាស្ត្រសំរាប់ណែនាំដល់ប្រជាពលរដ្ឋឱ្យចេះជួយខ្លួនឯង និងប្រើប្រាស់អ្វីដែលមានក្នុងមូលដ្ឋាន ដើម្បីឆ្លើយតបពេលមានជួបគ្រោះអាសន្នកើតឡើង

## ៦. ក្រុមឆ្លើយតប និង ព័ត៌មាន :

ត្រូវបានបង្កើតឡើងដើម្បីធ្វើប្រតិបត្តិការផ្តល់ព័ត៌មានអំពីមុខសញ្ញាគ្រោះថ្នាក់ដោយធម្មជាតិ និងដោយមនុស្សដែលកើតឡើងនៅមូលដ្ឋានឃុំ-សង្កាត់។ ធ្វើការប៉ាន់ប្រមាណនូវតម្រូវការនិងការខូចខាត ព្រមទាំងរបាយការណ៍ការខូចខាត និងបង្ហាញហេតុផល ព្រមទាំងធ្វើការអំពាវនាវរកជំនួយ ផ្តល់ជំនួយដល់អ្នករងគ្រោះ អនុវត្តគំរោងពលកម្ម ហើយមានតួនាទីទទួលខុសត្រូវដូចខាងក្រោម :

-សហការជាមួយអង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល កសាងគំរោងត្រៀមបង្ការគ្រោះមហន្តរាយតាមបែបរចនាសម្ព័ន្ធ និងមិនមែនរចនាសម្ព័ន្ធ

-រៀបចំទីសុវត្ថិភាពឱ្យមានលក្ខណៈសមស្របអាចស្នាក់នៅបាន

-ស្រង់ចំនួនប្រជាជនរងគ្រោះដែលជម្លៀសទៅរស់នៅតាមទីសុវត្ថិភាព

-ផ្តល់ការស្នាក់នៅដល់ប្រជាជនរងគ្រោះរៀបចំជំរកបណ្តោះអាសន្ន ឬនៅតាមគេហដ្ឋាន ដែលម្ចាស់គេអនុញ្ញាត

-គ្រប់គ្រងសំភារៈជំនួយសង្គ្រោះដូចជាអង្ករ ស្បៀងអាហារ...

-របាយការណ៍ពីស្ថានភាពជនរងគ្រោះ និងសកម្មភាពផ្តល់ជំនួយ វាយតំលៃការខូចខាត និងសេចក្តីត្រូវការ

-តាមដានត្រួតពិនិត្យសុខុមាលភាពរបស់ប្រជាជនរស់នៅក្នុងទីសុវត្ថិភាព

អាស្រ័យហេតុនេះ សូមឯកឧត្តមមេត្តាចាត់ចែងអនុវត្តស្របតាម ខ្លឹមសារខាងលើ តាមការគួរ ។

**ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស**

**អនុប្រធានទី១ គ.ជ.គ.ម**

ញឹម_វណ្ណដា